ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:០០៤......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី០០ ខែ ១ ឆ្នាំ ២០១០

# សារាចរ

## ស្តីពីការណែនាំ

## លើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

### I. សេចក្តីផ្តើម

១- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបែងចែកចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ និងអនុក្រឹត្យលេខ ១៦៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។ ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ និង អនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ១១៩៧ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ និង ប្រកាសលេខ ១១៩៦ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។ ដើម្បីឱ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ មានដំណើរការប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាពខ្ពស់ និងសម្រេចបានតាមគោលដៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តថវិកាថ្នាក់ជាតិសម្រាប់ឆ្នាំ ២០១១ ដែលមានតាមលំដាប់លំដោយដូចតទៅ :

២- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ត្រូវបានរៀបចំឡើងដោយផ្អែកលើ «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣**» ពិសេសដើម្បីគាំទ្រការអនុវត្ត «**យុទ្ធសាស្ត្រចតុកោណ *ដំណាក់កាលទី២***» ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភា និង បន្តរក្សាស្ថិរភាពនយោបាយ បន្តពង្រឹង និង ពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ បន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ធានាឱ្យបាននូវភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់

គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលនយោបាយគ្រឹះខាងសេដ្ឋកិច្ចស្តីពី *«ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងរយៈពេលវែងមានអត្រាខ្ពស់ប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និង មានកំណើនទុនបម្រុងជាប្រចាំ»* និង *«ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំ និង ការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេសក្នុងវិស័យអប់រំ សុខាភិបាល និង សមភាពយេនឌ័រ»* ព្រមទាំងឈានទៅសម្រេចបាននូវគោលដៅសហសវត្សរ៍កម្ពុជា ទាំង ៩ ។ ថវិកានេះ ក៏បានឆ្លុះបញ្ចាំងឱ្យឃើញផងដែរពីការខិតខំប្រឹងប្រែង និង ពុះពាររបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ និង កំណែទម្រង់លើគ្រប់វិស័យ និង កាន់តែស៊ីជម្រៅ ដូចជាកម្មវិធីអភិវឌ្ឍន៍វិស័យឯកជន និង យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ និង កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការបង្កើនអភិបាលកិច្ចល្អ និង ការបង្កើនការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពសេវាសាធារណៈ និង បម្រើប្រជាពលរដ្ឋបានកាន់តែប្រសើរឡើង ។

៣- ថវិកាឆ្នាំ ២០១១ នេះ បានឆ្លុះបញ្ចាំងអំពីអាទិភាពចំណាយរបស់រាជរដ្ឋាភិបាលទៅលើវិស័យអប់រំ សុខាភិបាល កសិកម្ម កសិ-ឧស្សាហកម្ម ធារាសាស្ត្រ អភិវឌ្ឍន៍ជនបទ និង ការបន្តពង្រឹង និង ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ស្ពាន ទំនប់ប្រឡាយ និង ប្រព័ន្ធស្រោចស្រព ដែលនៅតែជាមុខព្រួញសំខាន់ចាំបាច់ និងអាទិភាពរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ថវិកានេះក៏បានឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវឆន្ទៈនយោបាយដ៏មោះមុតរបស់រាជរដ្ឋាភិបាលក្នុងការបន្តជំរុញការអនុវត្តកម្មវិធីគោលនយោបាយ និង កម្មវិធីអភិវឌ្ឍន៍ជាអាទិភាព ពិសេសគោលនយោបាយជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ និង កម្មវិធីកំណែទម្រង់សំខាន់ៗ ដូចជាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ គោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ការពង្រឹងអភិបាលកិច្ចល្អ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដែលត្រូវបន្តអនុវត្តឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត ដើម្បីអាចបន្តរក្សាឱ្យបាននូវស្ថិរភាពនយោបាយ សុវត្ថិភាពសង្គម ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ធានាឱ្យបាននូវការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ និង ប្រកបដោយចីរភាព ព្រមទាំងបង្កើនបានភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និង គុណភាពសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង ។

៤- ដើម្បីសម្រេចបានតាមគោលដៅប្រកបដោយមហិច្ឆិតាខាងលើ រាជរដ្ឋាភិបាលត្រូវបន្តជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព រាល់ក្របខ័ណ្ឌច្បាប់ បទបញ្ជា និង វិធានការទាំងឡាយដែលមានស្រាប់ ព្រមទាំងបង្កើនការអប្បមាទជាប្រចាំ ដើម្បីដាក់ចេញនូវគោលនយោបាយ និង វិធានការជាក់ស្តែងបន្ថែមទៀត ដែលមានលក្ខណៈជាប្រព័ន្ធ មានភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាព ព្រមទាំងទាន់ពេលវេលា សំដៅពង្រឹងសមិទ្ធិផលជាសន្តិភាព ឯកភាពទឹកដី សន្តិសុខ ធានាបានស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងធានាបាននូវការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ការគ្រប់គ្រងអតិផរណា ការបង្កើតបាននូវបរិស្ថានកាន់តែអនុគ្រោះសម្រាប់សកម្មភាពសេដ្ឋកិច្ច និង ធុរៈកិច្ច ជាមួយនឹងការពង្រឹង និង ពង្រីកនូវប្រព័ន្ធសុវត្ថិភាពសង្គមជូនដល់ប្រជាពលរដ្ឋ ។

## II. លក្ខខណ្ឌ និង វិធានការក្នុងការអនុវត្តថវិកាឆ្នាំ ២០១១

### ក- ការអនុវត្តការប្រមូលចំណូល

៥-ដើម្បីឱ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ សម្រេចបានជោគជ័យជាពិសេស ដើម្បីឱ្យការអនុវត្តចំណូលសម្រេចបានតាមការគ្រោងទុក គឺ ដើម្បីឱ្យការប្រមូលចំណូលថវិការដ្ឋសរុបសម្រេចបានតាមគោលដៅ ៩ ៧៦១ ០០៩ លានរៀល គឺស្មើនឹង ១៨,៨៨% នៃផសស បើធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ កើន ១៧,៣% ។ ដើម្បីសម្រេចបានតាមគោលដៅនេះ រាជរដ្ឋាភិបាលត្រូវបង្កើនការប្រមូលចំណូល (១) ចំណូលក្នុងស្រុកថវិការដ្ឋនឹងប្រមូលឱ្យបាន ៦ ៨១៨ ៥៥៩ លានរៀល ស្មើនឹង ១៣,១៩% នៃផសស បើធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ កើន ១៤,៥% ដែលក្នុងនោះ ចំណូលចរន្តថវិការដ្ឋមាន ៦ ៧៦១ ៥៥៩ លានរៀល ស្មើនឹង ១៣,០៨% នៃផសស កើន ១៤,៤% (ចំណូលសារពើពន្ធថវិការដ្ឋមាន ៥ ៧១៦ ៣៨៤ លានរៀល ស្មើនឹង ១១,០៥% នៃផសស កើន ១៣,៥% និង ចំណូលមិនមែនសារពើពន្ធថវិការដ្ឋមាន ១ ០៤៥ ១៧៥ លានរៀល ស្មើនឹង ២,០២% នៃផសស កើន ១៩,៦%) និង ចំណូលមូលធនក្នុងប្រទេសមាន ៥៧.០០០ លានរៀល ស្មើនឹង ០,១១% នៃផសស កើន ១៨,៨% និង (២) ចំណូលមូលធនក្រៅប្រទេសនឹងប្រមូលឱ្យបាន ២ ៩៤២ ៤៥០ លានរៀល ស្មើនឹង ៥,៦៩% នៃផសស បើធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ កើន ២៤,៥% ដែលក្នុងនោះចំណូលមូលនិធិទ្រទ្រង់ថវិកាមាន ៣៤២ ៤៥០ លានរៀល ស្មើនឹង ០,៦៦% នៃផសស ថយចុះ ៥,៩% និង ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសមាន ២ ៦០០ ០០០ លានរៀល ស្មើនឹង ៥,០៣% នៃផសស កើន ៣១%។

៦- ថវិកាឆ្នាំ ២០១១ បានឆ្លុះបញ្ចាំងពីកំណើនចំណូលក្នុងស្រុកថវិការដ្ឋប្រមាណ ១៤,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលក្នុងនោះ ចំណូលក្នុងស្រុកជាថវិកាថ្នាក់ជាតិមាន ៦ ៥៥៦ ៦៥២ លានរៀល ស្មើនឹង ១២,៦៨% នៃផសស កើន ១៤,២% និងជាថវិការាជធានី-ខេត្តមាន ២៦១ ៩០៧ លានរៀល ស្មើនឹង ០,៥១% នៃផសស កើន ២១,៧% ។ ដើម្បីសម្រេចបានតាមគោលដៅនេះ គឺ (១) ចំណូល

ចរន្តថវិកាថ្នាក់ជាតិនឹងប្រមូលបានឱ្យបាន ៦ ៨៩៩ ៦៩២ លានរៀល ស្មើនឹង ១២,៥៧% នៃផសស បើធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ កើន ១៤,២% ដែលក្នុងនោះ ចំណូលសារពើពន្ធថ្នាក់ជាតិមាន ៥ ៤៧៦ ៨២៣ លានរៀល ស្មើនឹង ១០,៥៩% នៃផសស កើន ១៣,១% (ចំណូលគយ និងរដ្ឋាករ មាន ២ ៨៩២ ០០០ លានរៀល ស្មើនឹង ៥,៥៩% នៃផសស កើន ១១,២% ចំណូលពន្ធដារមាន ២ ៤១៤ ០០០ លានរៀល ស្មើនឹង ៤,៦៧% នៃផសស កើន ១៦,១% និង ចំណូលសារពើពន្ធថ្នាក់ជាតិផ្សេងៗទៀតមាន ១៧០ ៨២៣ លានរៀល ស្មើនឹង ០,៣៣% នៃផសស កើន ៦,៤%) និង ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិមាន ១ ០២២ ៨២៩ លានរៀល ស្មើនឹង ១,៩៨% នៃផសស កើន ២០% និង (២) ចំណូលចរន្តរាជធានី-ខេត្តនឹងប្រមូលឱ្យបាន ២៦១ ៩០៧ លានរៀល ស្មើនឹង ០,៥១% នៃផសស បើធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ កើន ២១,៧% ដែលក្នុងនោះ ចំណូលសារពើពន្ធរាជធានី-ខេត្តមាន ២៣៩ ៥៦១ លានរៀល ស្មើនឹង ០,៤៦% នៃផសស កើន ២៣,៦% និង ចំណូលមិនមែនសារពើពន្ធរាជធានី-ខេត្តមាន ២២ ៣៤៦ លានរៀល ស្មើនឹង ០,០៤% នៃផសស កើន ៤%។

៧- ដើម្បីសម្រេចបានតាមគោលដៅខាងលើ អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវរៀបចំអនុវត្ត និងតាមដានជាប្រចាំនូវកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលម្អិតទៅតាមខែ ។ បើគិតជាមធ្យមភាគប្រចាំខែ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចប្រមូលចំណូលពន្ធដែលជាចំណូលថវិកាថ្នាក់ជាតិឱ្យបានជា មធ្យម ២០១ ១៦៧ លានរៀល ក្នុងមួយខែ ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានភារកិច្ចប្រមូលចំណូលពន្ធ និងអាករ ដែលជាចំណូលថវិកាថ្នាក់ជាតិឱ្យបានជាមធ្យម ២៤១ ០០០ លានរៀល ក្នុងមួយខែ និង ចំណូលសារពើពន្ធផ្សេងៗទៀតទាំងថ្នាក់ជាតិ និង រាជធានី-ខេត្តត្រូវប្រមូលឱ្យបានជាមធ្យម ៣៤ ១៩៩ លានរៀល ក្នុងមួយខែ ទោះជាការប្រមូលជាក់ស្តែងអាចមានកម្រិតខ្ពស់ ឬ ទាបជាងការគ្រោងទុកបន្តិចបន្តួចទៅតាមស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏ដោយ ។ ទន្ទឹមនឹងនេះ កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលម្អិត និងទៅតាមប្រភេទ និងមាតិកាចំណូលនីមួយៗ ហើយប្រគល់ឱ្យតាមសាខា ទីស្នាក់ការ ឬ/និង មន្ត្រីដែលមានភារកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត ។

៨- ដើម្បីឱ្យការប្រមូលចំណូលមិនមែនសារពើពន្ធឆ្នាំ ២០១១ នេះ សម្រេចបានតាមគោលដៅ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរបស់ខ្លួននៅតាមរាជធានី-ខេត្ត ត្រូវរៀបចំកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាសដែលមានការ បែងចែកលម្អិតតាមខែ ដោយផ្អែកលើកិច្ចសន្យានៃការជួលទ្រព្យសម្បត្តិរដ្ឋ កិច្ចសន្យាសម្បទាននានា ចំណូលពីសេវាបង់ថ្លៃ សកម្មភាពអាជីវកម្ម និងសង្កេតនៃការប្រមូលចំណូលកន្លងមក ព្រមទាំងដាក់ផែនការសកម្មភាព និងវិធានការអនុវត្តលម្អិត និងទៅតាមប្រភេទ និងមាតិកាចំណូលនីមួយៗ ហើយប្រគល់ទៅឱ្យអង្គភាពក្រោមឱវាទនៅរដ្ឋបាលកណ្តាល និងនៅរាជធានី-ខេត្ត ដែលមានភារកិច្ច និងការទទួល

ខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត ។ អង្គភាពប្រមូលចំណូលត្រូវធ្វើការតាមដាន និងជំរុញជាប្រចាំនូវការអនុវត្ត កម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និង រិះរកវិធានការទាន់ពេលវេលា ក្នុងករណីចាំបាច់ ជាពិសេសត្រូវគោរព និង អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែន សារពើពន្ធលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ។ ទន្ទឹមនឹងនេះ ដើម្បីឱ្យការអនុវត្តកម្មវិធីប្រមូល ចំណូលប្រចាំត្រីមាសសម្រេចបានប្រកបដោយប្រសិទ្ធភាពខ្ពស់ អង្គភាពនីមួយៗត្រូវធ្វើការតាមដាន និងត្រួត ពិនិត្យជាប្រចាំ (ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និង ប្រចាំត្រីមាស) លើលទ្ធផលសម្រេចបាន ដើម្បីរិះរក វិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ព្រមទាំងធ្វើរបាយការណ៍អនុវត្តចំណូលប្រចាំសប្តាហ៍ ប្រចាំខែ និង ប្រចាំត្រីមាស ស្តីពីការអនុវត្តចំណូលរបស់ខ្លួនសម្រាប់ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និង មានវិធានការ តាមរយៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលើកឡើងពីលទ្ធផលដែលសម្រេចបាន និង ចំណុចខ្វះខាត ដែល បានកត់សំគាល់ ព្រមទាំងលើកឡើងនូវសំណូមពរ និង អនុសាសន៍ដើម្បីកែលម្អ និងបង្កើនប្រសិទ្ធភាពប្រមូល ចំណូល ។ ជាមួយនេះ នឹងបន្តអនុវត្តវិធានការកៀរគរចំណូល និងវិធានការតឹងទារបំណុល តាមរយៈក្រុមការងារ ទាំង ៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីវិស័យ និង ពីមុខសញ្ញាចំណូលដែលមានសក្តានុពលមួយចំនួន រួម មាន: (១)- ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ និង ឯកជនភាវូបនីយកម្ម (២)- ចំណូលពីដីសម្បទានសេដ្ឋកិច្ច ការជួលវិនិយោគកោះ សម្បទានលើហេដ្ឋារចនាសម្ព័ន្ធនានា និង ទីតាំងផ្សេងទៀត (៣)- ចំណូលពីវិស័យ ប្រៃសណីយ៍ ទូរគមនាគមន៍ លិខិតឆ្លងដែន ទិដ្ឋាការ និង វិស័យអាកាសចរស៊ីវិល (៤)- ចំណូលពីសហគ្រាស សាធារណៈ គ្រឹះស្ថានសាធារណៈ កូតានាំចេញ និង សម្បទានរ៉ែផ្សេងៗ និង (៥)- ចំណូលពីប្រេង និង ឧស្ម័ន ។

៩- លើសពីនេះទៅទៀត ដើម្បីធានាការប្រមូលចំណូលតាមគោលនយោបាយខាងលើនេះ ជាពិសេស ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានដាក់ចេញ នូវបណ្តាវិធានការមួយចំនួនដូចខាងក្រោម :

*<u>ទីមួយ- ការពង្រឹងសមត្ថភាពរបស់រាប់សម្រាប់គ្រប់គ្រង និង ប្រមូលចំណូល:</u>*

- បញ្ចប់ការរៀបចំ និង ដាក់ឱ្យអនុវត្តនូវបង្កាន់ដៃបង់ប្រាក់មួយដែលឯកភាព សម្រាប់ប្រើប្រាស់ក្នុងការ ចុះបញ្ជី និង តាមដានការគ្រប់គ្រងលើការប្រមូលចំណូលគ្រប់ប្រភេទ ។

- បន្តជំរុញការរៀបចំយន្តការ និង ការណែនាំឱ្យអនុវត្តយ៉ាងម៉ឺងម៉ាត់ និង ប្រកបដោយប្រសិទ្ធភាព នូវរាល់គោលការណ៍ច្បាប់ បទបញ្ជា និង វិន័យលើការប្រមូលចំណូលថវិកាថ្នាក់ជាតិគ្រប់ប្រភេទ ជាពិសេស ចំណូលមិនមែនសារពើពន្ធ ។

- បន្តជំរុញការសិក្សាស្វែងរកជំរើស និងយន្តការក្នុងការបង្កើនការប្រមូល ការពង្រីកមូលដ្ឋាន និង ការគ្រប់គ្រងចំណូល ប្រកបដោយប្រសិទ្ធភាព ពិសេសចំណូលពីប្រភពធនធានធម្មជាតិ ដូចជាប្រេង រ៉ែ និង ឧស្ម័ន ។ រាជរដ្ឋាភិបាលបន្តជំរុញ ការបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងរបស់ដែលហៅថា «ចំណាយ របស់ក្រុមហ៊ុនក្នុងការរុករក និង អភិវឌ្ឍន៍អាជីវកម្ម ប្រេង រ៉ែ និងឧស្ម័ន» ដើម្បីធានាថា ការគណនា និងការ

គ្រប់គ្រងចំណូលដែលបានមកពីប្រេង រ៉ែ និងឧស្ម័ន ត្រូវបានគណនា និង គ្រប់គ្រងឈរលើមូលដ្ឋានស្មោះត្រង់ ច្បាស់លាស់ និងត្រឹមត្រូវ ។

- ជំរុញបញ្ចប់ការកសាងគោលនយោបាយចំណូលរយៈពេលមធ្យម និង ដាក់ឱ្យអនុវត្ត ដើម្បីបង្កើនសមត្ថភាព និងសុក្រឹតភាពនៃការព្យាករណ៍ចំណូល សំដៅធានានិរន្តរភាព និង ស្ថិរភាពនៃហិរញ្ញវត្ថុសាធារណៈ ក៏ដូចជា ម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងការធ្វើសមាហរណកម្មនៃការកៀរគរធនធានថវិកាសំដៅបម្រើឱ្យការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម.។

- បន្តជំរុញការអនុវត្ត ព្រមទាំងបង្កើនសុក្រឹតភាព និង ប្រសិទ្ធភាពនៃ *ផែនការយុទ្ធសាស្ត្រថវិកា* ដែលជាឧបករណ៍ដ៏សំខាន់សម្រាប់ការធ្វើសមាហរណកម្មចំណូល និង ចំណាយទាំងក្នុង និង ក្រៅប្រទេសសម្រាប់រយៈពេលមធ្យមទៅក្នុងដំណើរការ នៃការកសាងថវិកាឯកភាពមួយ ដើម្បីបង្កើនភាពគ្រប់ជ្រុងជ្រោយ និង ជាបណ្តើរៗធានាបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ។

- បន្តជំរុញការកំណត់ឱ្យបានច្បាស់លាស់នូវបំណុលពន្ធ និង បំណុលនៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំផែនការប្រមូល និងអនុវត្តវិធានការតឹងទារឱ្យមានប្រសិទ្ធភាព ។

- បន្តជំរុញការបង្កើតក្របខ័ណ្ឌ សម្រាប់កៀរគរ និង បែងចែកចំណូលទៅតាមគ្រប់លំដាប់ថ្នាក់រដ្ឋបាល និង ផ្តល់ការណែនាំដល់ការកសាងវិធានការសំដៅបង្កើនធនធានទៅតាមរាជធានី-ខេត្ត និង ឃុំ-សង្កាត់ ក្រោមកម្មវិធីវិសហមជ្ឈការសារពើពន្ធ ។

- បន្តជំរុញពង្រឹងការងារសវនកម្ម ទាំងសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន ទាំងការងារអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ។

*ទីពីរ- ការកៀរគរចំណូលផ្នែកគយ និង រដ្ឋាករ:*

- បន្តជំរុញការរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីគយ ពិសេសបន្តជំរុញការអនុវត្តជាប្រព័ន្ធនូវយុទ្ធសាស្ត្រ និង កម្មវិធីការងារកំណែទម្រង់ និង ទំនើបកម្មរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ឆ្នាំ២០០៩-២០១៣ ក្នុងក្របខ័ណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ ។

- ជំរុញប្រសិទ្ធភាពអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ និងបន្តកែលម្អនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ-ចូល ដោយតម្រូវឱ្យមានការរៀបចំជា ក្រុមហ៊ុននាំចេញ-នាំចូល និង ក្រុមហ៊ុនដឹងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និង ភាពងាយស្រួលក្នុងការត្រួតពិនិត្យ និង ក្នុងការយកពន្ធ និង អាករផ្សេងៗ ជាពិសេសការអនុវត្តយន្តការសវនកម្ម ក្រោយពេលបញ្ចេញទំនិញពីគយ ដើម្បីរក្សាតុល្យភាពរវាងកិច្ចសម្រួលពាណិជ្ជកម្ម ជាមួយនឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ អាករគយ និង

ការលើកកម្ពស់អនុលោមភាពច្បាប់ កាត់បន្ថយការជ្រាបចេញនូវទំនិញពន្ធ អាករ បន្ទុករដ្ឋ ចូលទីផ្សារក្នុងស្រុក និងការរំលោភបំពានរបបព្យួរពន្ធផ្សេងៗទៀត ។

- បន្តរៀបចំកែលម្អនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ។

- បន្តជំរុញការអនុវត្តវិធានការតឹងរ៉ឹងក្នុងការបង្កើនចំណូលពន្ធគយរួមមានៈ

▪ *បន្តពង្រឹងការអនុវត្តបណ្តាវិធានការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ* ដោយសហការយ៉ាងជិតស្និទ្ធ ជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពថែមទៀតក្នុងការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តភារកិច្ចនេះត្រូវយកចិត្តទុកដាក់ ជាពិសេសលើវិធានការកែលម្អផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេទយិតភាព ដូចជា គេលសិលា យានយន្ត បរិក្ខារអេឡិចត្រូនិច និងបណ្តាទំនិញមានវេទយិតភាពចំណូលអោយមានប្រសិទ្ធភាពខ្ពស់ ជាពិសេសនៅតាមតំបន់សមុទ្រ និងនៅចុងទី រួមទាំងការជំរុញការដាក់អោយដំណើរការពេញលេញនូវអង្គភាពនាវាចរណ៍គយ ព្រមទាំងការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

▪ *បន្តពង្រឹងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និង ផ្លាស់ប្តូរព័ត៌មាន* រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និង កាតព្វកិច្ចពន្ធដារ ។ ជាមួយគ្នានេះដែរ អគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងផ្តល់ព័ត៌មានពីការនាំចូលទំនិញ មកអគ្គនាយកដ្ឋានពន្ធដារអោយបានទៀតទាត់ និងរៀងរាល់ខែ បន្ទាប់ពីក្រុមហ៊ុនបាននាំចូល ។

▪ *បន្តវិភាគ និងដាក់ឱ្យអនុវត្តនូវវិធានការច្បាស់លាស់ និងទន់ភ្លន់* លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល ។

▪ *ជំរុញកែសម្រួលនីតិវិធី នៃការគ្រប់គ្រងផលិតផលគេលសិលានាំចូលអោយមានភាពច្បាស់លាស់ងាយស្រួលក្នុងការកំណត់មុខសញ្ញាល្មើស និងការបង្ក្រាបកណ្តាលទី និងចុងទី រួមមានការគ្រប់គ្រងធុងផ្ទុកការគ្រប់គ្រងលិខិតដឹកជញ្ជូន និងការតម្រូវអោយចែកចាយតែតាមស្ថានីយ៍ដែលមានម៉ាកសញ្ញាក្រុមហ៊ុននាំចូលស្របច្បាប់នូវផលិតផលទាំងនេះតែប៉ុណ្ណោះ ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារនឹងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីចុះធ្វើការត្រួតពិនិត្យការលក់ប្រេងនៅតាមស្ថានីយ៍លក់ប្រេង ដែលមិនមានដាក់ស្លាកសញ្ញា ។*

▪ ជំរុញដាក់អោយអនុវត្តនូវគោលនយោបាយជាតិ ពាក់ព័ន្ធនឹងការងារទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធអោយបានឆាប់ ជាពិសេសកំណត់អោយបានច្បាស់លាស់នូវតួនាទី ភារកិច្ច ដែនសមត្ថកិច្ច និងការគ្រប់គ្រងមន្ត្រីរាជការគយ ដែលទទួលបន្ទុកការងារទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធគ្រប់ថ្នាក់ ។

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និង រដ្ឋាករ មានជាអាទិ៍ៈ បន្តការបណ្តុះបណ្តាល និង ការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និង សីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលគយឱ្យបានរឹងមាំ ។

- ពិនិត្យស៊ីជំរៅគោលនយោបាយពន្ធ អាករគយ ឈានទៅកែសម្រួលអាករលើការនាំចេញ-នាំចូលមួយចំនួន ជាពិសេសយានយន្ត កៅស៊ូកែច្នៃ និងទំនិញរសើបផ្សេងទៀត ដើម្បីរក្សាតុល្យភាពចំណូលដែលបាត់បង់ដោយការបញ្ចុះអត្រាពន្ធគយ តាមស្មារតីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ក៏ដូចជាឈានទៅកាត់បន្ថយអំពើរត់ពន្ធ តាមរយៈការកាត់បន្ថយគំលាតតម្លៃទំនិញរសើបលក់រាយតំបន់ព្រំដែនជាមួយប្រទេសជិតខាង ។

- បន្តចាត់វិធានការបន្ថែមទៀត ដើម្បីជំរុញឱ្យម៉ូតូដែលបានធ្វើស្ថិតិរួចហើយប្រមាណ ២០ ម៉ឺនគ្រឿងមកបង់ពន្ធនាំចូលឱ្យបានទាន់ពេលវេលា ។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានឹងធ្វើការសិក្សា អំពីការយកពន្ធលើការនាំចូលប្រេង ព្រោះការប្រើប្រាស់ប្រេងបច្ចុប្បន្នមិនមែនពាក់ព័ន្ធតែម្ចាស់រថយន្ត ឬម៉ូតូប៉ុណ្ណោះទេ ប៉ុន្តែវាប៉ះពាល់ដល់ប្រសិទ្ធភាពនៃសេដ្ឋកិច្ចទាំងមូល ជាពិសេសការប្រើប្រាស់ប្រេងសម្រាប់ការស្រោចស្រពដំណាំស្រូវតែម្តង ។

- បន្តពង្រឹង និង ពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និង យន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលម្អប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និង លើកកំពស់គុណភាពសេវាកម្មជូនដល់អតិថិជន ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អោយបំពេញការងារប្រកបដោយការទទួលខុសត្រូវ និងស្មារតីលះបង់ ដោយឈរលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិជាធរមាន រាប់បញ្ចូលទាំងលទ្ធភាពដាក់ទណ្ឌកម្មចំពោះមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ដែលឃុបឃិត ធ្វេសប្រហែស ឬគ្មានសមត្ថភាពបណ្តែតបណ្តោយអោយមានការរត់ពន្ធ ។

*<u>ទីបី- ការកៀរគរចំណូលពន្ធដារៈ</u>*

- ជំរុញការអនុវត្តជាប្រព័ន្ធនូវកម្មវិធីកែលម្អគោលនយោបាយ និងពង្រឹងរដ្ឋបាលសារពើពន្ធ ក្នុងក្របខ័ណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ។

- បន្តជំរុញការរៀបចំក្របខ័ណ្ឌគតិយុត្ត ដើម្បីអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ ក្នុងឆ្នាំ២០១១នេះ

- បន្តពង្រឹងការអនុវត្តកម្មវិធីកែលម្អរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ។

- បន្តបញ្ចប់ការកសាង និង ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- បន្តពង្រឹងការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ និង ឱ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង វិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។

- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និង ពង្រឹងការអនុវត្តរបបពិតនៅតាមបណ្តារាជធានី-ខេត្ត និង បន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ អោយជិតទៅនឹងការលក់ជាក់ស្តែង ។

- បន្តបណ្តុះបណ្តាល និង បង្កើនសមត្ថភាពវិជ្ជាជីវៈ និង សីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលពន្ធដារឱ្យបានរឹងមាំក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និង មធ្យម ព្រមទាំងធ្វើការជ្រើសរើសមន្ត្រីថ្មីបន្ថែមទៀត ។ មន្ត្រីដែលត្រូវជ្រើសរើស គឺមូលដ្ឋានណា៎ះមន្ត្រីបម្រើការងារត្រូវជ្រើសរើសសិស្ស ឬនិស្សិតដែលមានសញ្ញាបត្រចាប់ពីមធ្យមសិក្សាបត្រភាគទី២ឡើងទៅ ហើយមានអាសយដ្ឋានស្ថិតនៅទីនោះ ។

- ជំរឿនអ្នកជាប់ពន្ធនៅតាមរាជធានី- ខេត្ត ក្នុងនោះមានជំរឿនសហគ្រាស យានយន្ត អចលនទ្រព្យ និងដីធ្លីមិនបានប្រើប្រាស់ សំដៅពង្រីកមូលដ្ឋានជាប់ពន្ធ ប្រមូលពន្ធអោយអស់លទ្ធភាព ។

- រៀបចំអនុវត្តច្បាប់ធរមាន ដោយរៀបចំលិខិតបទដ្ឋាន ដើម្បីដាក់អោយអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីពន្ធលើអចលនទ្រព្យ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញមូលធន និងបទប្បញ្ញត្តិស្តីពីពន្ធលើភតិសន្យា

- រៀបចំគោលនយោបាយសារពើពន្ធ ក្នុងនោះមានការរៀបចំ តម្រូវសន្និសញ្ញាស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ច្បាប់ស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងឧស្ម័ន ច្បាប់ស្តីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ ជាអាទិ៍មាន រ៉ែមាស និងលោហធាតុ និងត្បូងថ្មមានតម្លៃដទៃទៀត និង ថ្ម ខ្សាច់ ដី ។

- អប់រំពន្យល់ណែនាំ ដោយផ្ទាល់ និងតាមរយៈការផ្សព្វផ្សាយសេចក្តីជូនដំណឹង និងសៀវភៅណែនាំនានា ដើម្បីអោយអ្នកជាប់ពន្ធបានយល់ច្បាស់លាស់ពីកាតព្វកិច្ចរបស់ខ្លួន គោរពប្រតិបត្តិច្បាប់ពន្ធដារល្អប្រសើរដោយស្ម័គ្រចិត្ត និងបង់ប្រាក់ពន្ធបានត្រឹមត្រូវ ។

- អនុវត្តវិធានការបង្ខំ ក្នុងនោះមានការធ្វើសវនកម្ម និងការទារបំណុលពន្ធ ដែលត្រូវបន្តវិធានការតឹងទារបំណុលពន្ធអោយបានខ្លាំងក្លាចំពោះអ្នកជាប់ពន្ធដែលជំពាក់បំណុលពន្ធច្រើន ហើយមិនអើពើអំពីការទូទាត់អោយជ្រះស្រឡះ ។ វិធានការតឹងទារដែលអគ្គនាយកដ្ឋាននឹងកំពុងបន្តអនុវត្ត រួមមានៈ

- សហការជាមួយធនាគារជាតិ និងធនាគារ អោយឃាត់ទុកគណនីអ្នកជំពាក់បំណុលពន្ធ
- ស្នើសុំកិច្ចសហការពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បញ្ឈប់ប្រតិបត្តិនាំចេញ- នាំចូល ចំពោះអ្នកជំពាក់បំណុលពន្ធដែលមានសកម្មភាពនាំចេញ- នាំចូល
- ស្នើសុំអោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធ្វើការព្យួរការពិនិត្យឯកសារវិនិយោគរបស់សហគ្រាសដែលជំពាក់បំណុលពន្ធ
- ព្យួរទុកការផ្ទេរកម្មសិទ្ធិកាន់កាប់អចលនទ្រព្យ

▪ ដំណើរការក្តីបំណុលពន្ធទៅតុលាការចំពោះសហគ្រាសចំនួនមួយចំនួន ។ល។

- បន្តធ្វើការសិក្សាអំពីវិធានការពោធកម្មបន្ត និង លទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង បណ្តាច្បាប់ពាក់ព័ន្ធក្នុងគោលដៅបង្កើនចំណូលវិភាគពិត ដែលក្នុងនោះនឹងពិចារណាធ្វើវិសោធនកម្មមាត្រា ២ នៃអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែខ្វះ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម ដើម្បីបញ្ចុះផលរបរ និងបង្កើនចំនួនអ្នកជាប់ពន្ធ តាមរបបឆ្លើយប្រកាសពោយបានច្រើន ។

- ធ្វើការប្រមូលពន្ធលើការលក់ទំនិញ ហូបចុក និងសេវាកម្មផ្សេងៗ ដែលមិនមែនជាសកម្មភាព ឬជាមុខរបររបស់ក្រុមអ្នកកាស៊ីណូ ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ .

<u>*ទីបទ- ការពង្រឹងការគ្រប់គ្រងនៃ ការកៀរគរចំណូលមិនមែនសារពើពន្ធ:*</u>

- បង្កើនការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- ពង្រឹងការគ្រប់គ្រងសហគ្រាសសាធារណៈ ពិសេសការបង់ភាគលាភ និង ការបង់ពន្ធលើប្រាក់ចំណេញជូនរដ្ឋ ។

- បង្កើនការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

- បន្តស្រាវជ្រាវ និង កំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និង បណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីអាកាសចរស៊ីវិល ពេលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រ សហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការប្រមូលចំណូល ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមរយៈការពង្រឹងបន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់ បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់

រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

- បន្តជំរុញការអនុវត្តការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និង ការអនុញ្ញាតលើការប្រកបសេវាកម្មវាយតម្លៃ និង ការជួញដូរអចលនវត្ថុ ដើម្បីពង្រឹងការគ្រប់គ្រងទីផ្សារ និង ការប្រមូលពន្ធ ។

- បន្តចុះសិក្សា និង ស្រាវជ្រាវរាល់បំណុលទាំងអស់ ដើម្បីរៀបចំគោលការណ៍ និង នីតិវិធីតឹងទារ ឬ ដោះស្រាយ តាមផ្លូវច្បាប់ចំពោះបំណុលរ៉ាំរ៉ៃ ។ ពិសេស កំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និង បណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះតាមគ្រប់មុខសញ្ញាទាំងអស់ តាមរយៈក្រុមការងារទាំង ៥ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីអាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រសហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តរៀបចំយន្តការ និង ដាក់ចេញនូវវិធានការដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ និង ស្ថាប័ន សម្រាប់ការគ្រប់គ្រង និង ប្រមូលចំណូលមិនមែនសារពើពន្ធ ។

- បន្តពង្រឹងការគ្រប់គ្រងឯកជនភាវូបនីយកម្មនៃទ្រព្យសម្បត្តិរដ្ឋឱ្យស្របទៅតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការពង្រឹងការប្រមូលចំណូលពីការជួល ឬ លក់អចលនទ្រព្យ ការពង្រឹងនៃការគ្រប់គ្រងសហគ្រាសសាធារណៈ ព្រមទាំងពង្រឹងការគ្រប់គ្រងចំណូលពីធនធានធម្មជាតិគ្រប់ប្រភេទ ។

- ពង្រឹងក្របខ័ណ្ឌច្បាប់ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពអាជីវកម្មកាស៊ីណូ និងអាជីវកម្មល្បែងផ្សេងទៀត ដូចជាអាជីវកម្មកម្រៃជើងសារ (Rolling) អាជីវកម្មល្បែងភ្នាល់បាល់ ល្បែងភ្នាល់បក្សី (ជល់មាន់) ប្រណាំងសេះ ល្បែងភ្នាល់ផ្សេងៗ អាជីវកម្មល្បែងតាម internet និង អាជីវកម្មផ្សេងទៀត ដែលស្ថិតនៅក្នុងបរិវេណកាស៊ីណូ និង បានទទួលការឯកភាពពីរាជរដ្ឋាភិបាលរួចហើយ ព្រមទាំងបង្កើនការយកពន្ធពីអាជីវកម្មល្បែងទាំងនោះអោយអស់ពីលក្ខានុពល ដើម្បីធានានូវកំណើនចំណូលពីវិស័យនេះ ។

- រៀបចំដាក់ឱ្យអនុវត្តបង្កាន់ដៃបង់ប្រាក់មួយដែលឯកភាព

- បន្តជំរុញការអនុវត្តប្រព័ន្ធដែលផ្តល់អំណាចដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការអនុម័តជាចុងក្រោយលើរាល់កិច្ចព្រមព្រៀង និង កិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីបង្កើនចំណូលពីសម្បទានរបស់រដ្ឋ និង ដើម្បីការពារផលប៉ះពាល់ជាអវិជ្ជមានដល់ថវិកាជាតិ ។

- ផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រង និង ពង្រឹងយន្តការប្រមូលចំណូលពីភាសីគ្រប់ប្រភេទ និង សត្តឃាត ។

- យកចិត្តទុកលើការកាតព្វកិច្ចបង់ភាគលាភនៃប្រាក់ចំណេញជូនរដ្ឋ ចំពោះសហគ្រាសសាធារណៈមួយចំនួន និងពង្រឹងយន្តការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាលមួយចំនួន ដែលមានចំណូល ប៉ុន្តែប្រើប្រាស់ថវិការដ្ឋ ដូចជាសកលវិទ្យាល័យ និងមន្ទីរពេទ្យរដ្ឋមួយចំនួន ។

- ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីដែលទទួលបន្ទុកការងារប្រមូលចំណូល ។

**ខ- ការអនុវត្តចំណាយថវិកា**

**១០-** ដើម្បីធានាដល់ការអនុវត្តថវិកាឆ្នាំ ២០១១ ប្រកបដោយប្រសិទ្ធភាព និង សម្រេចបានតាមគោលដៅនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស ដើម្បីបម្រើឱ្យការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាល ការគ្រប់គ្រងចំណាយត្រូវបន្តពង្រឹងបន្ថែមទៀត និង ត្រូវពង្រឹងការគោរពច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុ ជាពិសេសការគោរពឱ្យបានដាច់ខាតនូវវិន័យថវិកាទាំង ១១១ ។ ទន្ទឹមនឹងនេះ ត្រូវបន្តពង្រឹងការអនុវត្តអភិបាលកិច្ចល្អក្នុងការអនុវត្តថវិកា និងការគ្រប់គ្រងថវិកា ជាពិសេស ការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់ការកែលម្អលើការអនុវត្តថវិកា ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

*ខ.១-ការរៀបចំ និង ការអនុវត្តកម្មវិធីចំណូល-ចំណាយ*

**១១-** ដើម្បីឱ្យការអនុវត្តថវិកាប្រកបដោយភាពជឿទុកចិត្តបាន និង ប្រព្រឹត្តទៅដោយរលូន ជាពិសេសដើម្បីធានាការឆ្លើយតបទៅនឹងតម្រូវការចំណាយជាក់ស្តែងឱ្យទាន់ពេលវេលា ប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវរៀបចំគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសម្រាប់រយៈពេលពេញ ១ ឆ្នាំ ដែលមានបែងចែកលម្អិតទៅតាមខែ និង ទៅតាមគម្រូដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា និង នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ) ដោយឈរលើមូលដ្ឋាននៃតម្រូវការចំណាយជាក់ស្តែង (តាមប្រតិទិននៃផែនការសកម្មភាពការងារ និង ផែនការលទ្ធកម្ម) និង ក្នុងក្របខ័ណ្ឌនៃឥណទានដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។ ក្រសួង-ស្ថាប័ន ត្រូវផ្ញើកម្មវិធីចំណូល-ចំណាយដែលបានរៀបចំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា និងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ) ដោយឡែក មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ត្រូវផ្ញើកម្មវិធីចំណូល-ចំណាយដែលបានរៀបចំទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយច្បាប់ ដើម្បីបូកសរុបរួចផ្ញើមកនាយកដ្ឋានថវិកា និងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និង ផ្ញើទៅក្រសួង-ស្ថាប័ន ដែលជាខ្សែបណ្តោយរបស់ខ្លួនមួយច្បាប់សម្រាប់ការគ្រប់គ្រង និង តាមដានការអនុវត្ត ។ ក្រោយពីទទួលបានកម្មវិធីចំណូល-ចំណាយ ដែលស្នើឡើងដោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា

និងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ) ត្រូវពិនិត្យ និង វាយតម្លៃ ដោយផ្អែកទៅលើអាទិភាពនៃតម្រូវការ និង លទ្ធភាពចំណូលដែលអាចប្រមូលបាន ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសទៅតាមមាតិកាថវិកា សម្រាប់ការអនុវត្ត ។

១២- ដើម្បីបន្តធានា និង បង្កើនភាពជឿទុកចិត្តបានលើថវិកា ជាពិសេស ដើម្បីបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសឱ្យកាន់តែបានត្រឹមត្រូវ និងសុក្រឹត ព្រមទាំងការអនុវត្តឱ្យបានម៉ឺងម៉ាត់តាមកម្មវិធីចំណូល-ចំណាយនេះគឺជាប្រការចាំបាច់បំផុត។ ដូច្នេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និង អគ្គនាយកដ្ឋាន និង នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវនីតិវិធីដូចខាងក្រោមៈ

- នៅរៀងរាល់ថ្ងៃទី ២០ នៃខែនាចុងត្រីមាសនីមួយៗ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ញើមកនាយកដ្ឋានថវិកា និងអង្គភាពគ្រប់គ្រងសាច់ប្រាក់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្ត ដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី ១ និង ខែទី ២ និង ការប៉ាន់ស្មានអនុវត្តខែទី ៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ប្រសិនបើចាំបាច់ ។

- ដោយឡែកមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវផ្ញើរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី ១ និង ខែទី ២ និង ការប៉ាន់ស្មានអនុវត្តខែទី ៣ ជាមួយ នឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ប្រសិនបើចាំបាច់ទៅឱ្យមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ២០ នៃខែនាចុងត្រីមាសនីមួយៗ ដើម្បីទុកពេលវេលាឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុបូកសរុបរួចផ្ញើមកនាយកដ្ឋានថវិកា និងអង្គភាពគ្រប់គ្រងសាច់ប្រាក់ឱ្យបានទាន់ពេលវេលា ។

- នៅរៀងរាល់ថ្ងៃទី ២៥ នៃខែនាចុងត្រីមាសនីមួយៗ នាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំប្រជុំពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ត្រីមាសបន្ទាប់ ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល-ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ត្រូវរៀបចំប្រកាសប្រគល់កម្មវិធីចំណូល-ចំណាយ សម្រាប់ត្រីមាសបន្ទាប់ទៅតាមមាតិកាថវិកាក្នុងកម្រិតឥណទានអតិបរមាជូនដល់ក្រសួង-ស្ថាប័ននីមួយៗ និងមន្ទីរជំនាញ

រាជធានី-ខេត្តនីមួយៗ ដោយកម្លងជូននាយកដ្ឋានហិរញ្ញកិច្ច អគ្គនាយកដ្ឋានរតនាគារជាតិ និង គណៈអភិបាល រាជធានី-ខេត្ត ។

- អាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធិ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងវង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយនាយកដ្ឋានហិរញ្ញកិច្ច មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគាររាជធានី-ខេត្ត និង អគ្គនាយកដ្ឋានរតនាគារជាតិត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និង ត្រូវបើកជាសាច់ប្រាក់តែនៅក្នុងកម្រិតនៃកម្មវិធីចំណូល- ចំណាយ និងសាច់ប្រាក់ប្រចាំត្រីមាសនេះតែប៉ុណ្ណោះ ។

- អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវផ្ញើរបាយការណ៍អនុវត្តចំណូល-ចំណាយប្រចាំខែ មកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ១០ នៃខែ បន្ទាប់ ។

- អគ្គនាយកដ្ឋានរតនាគារជាតិត្រូវបញ្ជូនមកនាយកដ្ឋានថវិកានូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ របាយការណ៍បុរេប្រទាន និងតារាងតុល្យភាពនៃគណនីប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតម្លៃនូវសភាពការណ៍អនុវត្តធៀបនឹងខែមុនត្រីមាសមុននៃឆ្នាំនេះ និង ប្រៀបធៀបទៅនឹងខែត្រីមាសដូចគ្នានៃឆ្នាំមុន ។

- រតនាគារនៅថ្នាក់មូលដ្ឋានត្រូវបញ្ជូនមកមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស និង ដើម្បីឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើរបាយការណ៍ផ្ញើមកនាយកដ្ឋានថវិកា ។

## ខ.២- *ការផ្តល់ធានាចំណាយ*

- ទាំងថវិកាកម្មវិធី និងមិនមែនកម្មវិធី ការស្នើ និង ការផ្តល់ធានាចំណាយ ត្រូវអនុវត្តទៅតាមប្រភេទចំណាយធំៗបី ដូចខាងក្រោម:
  - ***ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)*** ពុំតម្រូវឱ្យមានការស្នើធានាចំណាយទេ ដោយបោះផ្សាយអាណត្តិបើកប្រាក់តែម្តង ដោយឈរលើមូលដ្ឋានឥណទានដែលមានទិដ្ឋាការបញ្ជាក់ពីចំនួនក្របខ័ណ្ឌ និងកាំប្រាក់ ពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។
  - ***ចំណាយដែលមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និង ចំណាយដែលមានរបបកំណត់ច្បាស់លាស់*** ពុំតម្រូវឱ្យមានការស្នើធានាចំណាយទេ ។ ចំណាយប្រភេទនេះ មានដូចជា

ការចំណាយតាមរយៈរដ្ឋទេយ្យបុរេប្រទាន និង ចំណាយឧបត្ថម្ភផ្សេងៗ ដែលមានគោលការណ៍កំណត់រួចហើយ ចំណាយលើអគ្គិសនី ទឹក ទូរសព្ទ ។

- *ចំណាយដែលតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ*: តម្រូវឱ្យមានការសុំធានាចំណាយស្របទៅតាមផែនការលទ្ធកម្ម លើកលែងតែករណីពិសេសខ្លះ ។ សម្រាប់ឆ្នាំ ២០១២ គឺអាចធានាចំណាយបាន លុះត្រាតែមានផែនការលទ្ធកម្ម ។

- ចំពោះប្រភេទចំណាយដែលមិនតម្រូវឱ្យមានការសុំធានាចំណាយ អាណាប័កត្រូវធ្វើអាណត្តិសុំទូទាត់តែម្តង ដោយមានភ្ជាប់មកជាមួយនូវឯកសារ និង លិខិតយុត្តិការគ្រប់គ្រាន់ស្របទៅតាមនីតិវិធីទូទាត់ ។

- មិនអនុញ្ញាតឱ្យមានការផ្តល់ធានាចំណាយ និង ការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ប្រសិនបើគ្មានការស្នើសុំជាលាយល័ក្ខណ៍អក្សរពីអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ ទោះបីចំណាយនោះមានកត់ត្រាទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុក៏ដោយ ។

- ត្រូវផ្តល់ធានាចំណាយតែក្នុងកម្រិតឥណទានថវិកាដែលបានអនុម័ត និង ដែលមាននៅសល់ទំនេរក្រោយពីដកស្តុក លើរាល់ការធានាចំណាយ និង ការចំណាយជាក់ស្តែង រួមទាំងថវិកាបុរេប្រទានផង ។

- មិនត្រូវផ្តល់ធានាចំណាយឱ្យលើសពីឥណទានថវិកាដែលមានលក្ខណៈកម្រិតកំណត់ ។

- មិនត្រូវផ្តល់ធានាចំណាយទៅលើការអនុវត្តនូវសកម្មភាព ដែលនាំឱ្យមានការជ្រើសរើសបុគ្គលិកថ្មី ឬ បុគ្គលិកជាប់កិច្ចសន្យានៅក្នុងឆ្នាំដែលកំពុងអនុវត្ត ដោយគ្មានការគ្រោងទុកក្នុងថវិកា ឬ គ្មានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល ។

- មិនត្រូវលើកសំណើចំណាយបន្ថែមប្រសិនបើគ្មានការសន្សំសំចៃពីខ្ទង់ចំណាយដទៃមកធានា ។

- ក្នុងការផ្តល់ធានាចំណាយមិនត្រូវកាត់បន្ថយសកម្មភាពការងារ អនុកម្មវិធី ឬកម្មវិធីដែលបានអនុម័តរួចហើយនោះទេ លើកលែងតែមានការស្នើសុំពីសាមីក្រសួង-ស្ថាប័ន ដោយមានបញ្ជាក់ពីហេតុផល និង ផលប៉ះពាល់ច្បាស់លាស់ ហើយធានាថាមិនធ្វើឱ្យប៉ះពាល់ដល់ការសម្រេចគោលដៅសូចនាករនៃគោលនយោបាយរបស់ក្រសួង-ស្ថាប័នដែលបានកំណត់ ឬ គោលនយោបាយរបសវិស័យ និង គោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ។

## ខ.៣- *ការធ្វើលទ្ធកម្មសាធារណៈ*

- ការធ្វើលទ្ធកម្មសាធារណៈ ត្រូវរៀបចំចងជា «ឡូតិ៍លទ្ធកម្ម» ឬ «កញ្ចប់លទ្ធកម្ម» អោយបានសមស្របចំពោះមុខសញ្ញាលទ្ធកម្ម ដែលមានលក្ខណៈបច្ចេកទេសដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា ។

- ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវពង្រឹងគោលការណ៍ និងនីតិវិធីរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ដោយផ្អែកលើកញ្ចប់ថវិកាប្រចាំឆ្នាំសារពើពន្ធដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាពពេលការពារថវិកា ផ្អែកលើតម្រូវការជាក់ស្តែង និង គោរពទៅតាមវិធីសាស្ត្រ និង

នីតិវិធីលទ្ធកម្មសាធារណៈ ហើយផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈ) ដើម្បីពិនិត្យ និងផ្តល់ការឯកភាព ។

- ការធ្វើលទ្ធកម្មសាធារណៈត្រូវអនុវត្តឱ្យបានទៀងទាត់ និង ទៅតាមប្រតិទិនដែលបានកំណត់នៅក្នុងផែនការលទ្ធកម្ម ។

- គ្រប់ក្រសួង-ស្ថាប័ន និង រាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈលក្ខណៈរដ្ឋបាលទាំងអស់ត្រូវធ្វើរបាយការណ៍ប្រចាំខែស្តីពីការអនុវត្តលទ្ធកម្ម រួមទាំងទិន្នន័យនៃកិច្ចសន្យា និង ការងារវិសហមជ្ឈការជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានលទ្ធកម្មសាធារណៈ) ឱ្យបានទៀងទាត់ ។

- គ្រប់ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវគោរពឱ្យបានម៉ឺងម៉ាត់ទៅតាមអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ សារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ ២០០៨ និងឆ្នាំបន្តបន្ទាប់ និង បទប្បញ្ញត្តិផ្សេងៗទៀតស្តីពីលទ្ធកម្មសាធារណៈ ។

- តម្លៃកិច្ចសន្យាលទ្ធកម្មមិនអនុញ្ញាតឱ្យលើសពីឥណទានថវិកាដែលបានផ្តល់ការធានាចំណាយឡើយ ។ ករណីលើសពីឥណទានដែលបានផ្តល់ពេលធានាចំណាយ ត្រូវមានការសម្របសម្រួលរវាងអង្គភាពដែលផ្តល់ធានាចំណាយ និង នាយកដ្ឋានលទ្ធកម្មសាធារណៈ ឬអង្គភាពលទ្ធកម្ម (ករណីក្រោមសិទ្ធិសម្រេច) ។

- មិនអនុញ្ញាតឱ្យធ្វើការប្រគល់ទទួលទំនិញ សំណង់ ឬសេវា ដោយគ្មានកិច្ចសន្យាលទ្ធកម្មឡើយ ព្រោះកិច្ចសន្យាជាមូលដ្ឋានសំខាន់ និង ចាំបាច់បំផុតសម្រាប់ធ្វើការទូទាត់ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់លក្ខណៈបច្ចេកទេស គុណភាព តម្លៃ រយៈពេលផ្គត់ផ្គង់ ឬ សាងសង់ ដែលភាគីទាំងពីរព្រមព្រៀងគ្នា ។

- ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានការផ្លាស់ប្តូរលក្ខណៈបច្ចេកទេសនៃទំនិញ សំណង់ ឬ សេវា ដែលកំណត់ក្នុងកិច្ចសន្យា ត្រូវតែមានការឯកភាពជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ និង មានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- ក្នុងករណីការងារដែលទទួលអនុវត្តដោយអង្គភាពរដ្ឋ ការទូទាត់ត្រូវរក្សាចំនួនទឹកប្រាក់ ១០% នៃតម្លៃសរុបរបស់កិច្ចសន្យាទុកជាការធានាគុណភាពជំនួសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា រហូតដល់ផុតរយៈពេលធានាគុណភាពទើបធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់ បន្ទាប់ពីមានកំណត់ហេតុប្រគល់ទទួលបញ្ជាក់ថា បានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា ។

### ខ.៤- *ការទូទាត់ និង ការបើកផ្តល់*

- គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវគោរពទៅតាមនីតិវិធី និង បទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ និង ការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសត្រូវរៀបចំសំណើសុំធ្វើការទូទាត់ទៅតាមលំដាប់លំដោយ នៃកម្មវិធីចំណាយប្រចាំខែឱ្យបានទៀងទាត់ ។

- មិនត្រូវអនុញ្ញាតឱ្យមានការលើកលែងគោលការណ៍នៃបរិបថចំណាយ ការសន្យាចំណាយ ការជំរះបញ្ជី ការធ្វើអាណត្តិបើកប្រាក់ និង ការទូទាត់ លើកលែងតែមានករណីដែលរាជរដ្ឋាភិបាលសម្រេចដោយឡែក ។
- ត្រូវធ្វើការទូទាត់ និង បញ្ចេញអាណត្តិបើកប្រាក់ទៅតាមកម្មវិធីចំណាយដែលបានកំណត់ ។
- មិនត្រូវអនុវត្តចំណាយ និង មិនត្រូវទូទាត់ជូនចំពោះចំណាយដែលគ្មានលិខិតយុត្តិការគ្រប់គ្រាន់ ។
- មិនត្រូវធ្វើអាណត្តិបើកប្រាក់ និង មិនត្រូវបញ្ជូនអាណត្តិបើកប្រាក់នោះទៅរតនាគាររាជធានី-ខេត្ត និង អគ្គនាយកដ្ឋានរតនាគារជាតិ ប្រសិនបើលិខិតយុត្តិការផ្លូវការមានលក្ខណៈមិនគ្រប់គ្រាន់ ។
- រជ្ជទេយ្យបុរេប្រទានមានពីរប្រភេទគឺ រជ្ជទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី ដែលមានទឹកប្រាក់នៃជំុបង្វិល ១ ភាគ ៨ លើ ៣០% នៃឥណទានសរុបលើជំពូកមួយចំនួនដែលមានតម្រូវការចំណាយ តាមរយៈរជ្ជទេយ្យបុរេប្រទាន និងរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី ដែលមានទឹកប្រាក់នៃជុំបង្វិល ១ ភាគ ៤ នៃឥណទានសរុបលើជំពូកមួយចំនួនដែលបានតម្រូវការចំណាយតាមរយៈរជ្ជទេយ្យបុរេប្រទាន ក្រោយពីបានដកចេញរួចហើយនូវឥណទានដែលទុកសម្រាប់ចំណាយតាមនីតិវិធីទូទាត់ត្រង់ ។ ទោះជារជ្ជទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី ឬ រជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីក៏ដោយចំនួនលើកនៃការទូទាត់ អាចអនុញ្ញាតឱ្យធ្វើបានលើសពីចំនួនជុំបង្វិល អាស្រ័យទៅតាមចំណាយជាក់ស្តែងដែលបានអនុវត្ត និង ត្រូវសុំបំពេញបេឡារជ្ជទេយ្យបុរេប្រទានឡើងវិញដើម្បីជៀសវាងការយឺតយ៉ាវក្នុងការទូទាត់ផង និង ដើម្បីកុំឱ្យស្ទះការងារផង ។ រាល់ការសុំទូទាត់ និង សុំបំពេញបេឡារជ្ជទេយ្យបុរេប្រទាន ត្រូវមានលិខិតយុត្តិការគ្រប់គ្រាន់ និង អនុវត្តទៅតាមតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន ។ ជាមួយគ្នានេះដែរ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវពង្រឹងការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវប្រកាសលេខ ០១៤ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ជាពិសេសពាក់ព័ន្ធនឹងមុខសញ្ញាចំណាយ តាមរយៈរជ្ជទេយ្យបុរេប្រទាន និងហាមដាច់ខាតការបំបែកប័ណ្ណចំណាយទៅតាមទីកន្លែង (គោលដៅចំណាយ) ពេលវេលា ទឹកប្រាក់ចំណាយ និង សមាសធាតុនៃមុខសញ្ញាចំណាយ ក្នុងគោលបំណងគេចវៀសការអនុវត្តនីតិវិធីលទ្ធកម្ម ឬ ការប្រើប្រាស់រជ្ជទេយ្យបុរេប្រទានជំនួសការអនុវត្តនីតិវិធីលទ្ធកម្ម ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពិនិត្យលទ្ធភាពកែសម្រួល និងធ្វើបច្ចុប្បន្នភាពប្រកាសខាងលើនេះ ដើម្បីសម្រួលដល់ការអនុវត្តអោយកាន់តែមានប្រសិទ្ធភាព ស្របតាមស្ថានភាពជាក់ស្តែង ។
- ការផ្តល់ថវិកាបុរេប្រទាន ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិ គោលការណ៍ និង នីតិវិធីដែលមានចែងនៅក្នុងអនុក្រឹត្យ លេខ ១៥៥ អនក្រ បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទាន សម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ ។
- អាចផ្តល់មូលនិធិជួសជុល-ថែទាំផ្លូវថ្នល់បាន លុះត្រាតែមានឥណទានសល់ទំនេរនៅក្នុងគណនីមូលនិធិ ។

• ការចេញអាណត្តិទូទាត់ ត្រូវធ្វើឡើងក្រោយពីការប្រគល់ទទួល និង ឱ្យស្របទៅតាមលក្ខខណ្ឌទូទាត់ក្នុងកិច្ចសន្យា ។

១៣- ទន្ទឹមនឹងការអនុវត្តចំណាយទៅតាមកម្មវិធីចំណាយ ដំណើរការទូទាត់អាណត្តិបើកប្រាក់ត្រូវផ្តល់អាទិភាពទៅលើចំណាយចាំបាច់ជាប្រចាំ មានដូចជាប្រាក់បៀវត្ស ប្រាក់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភតាមគោលនយោបាយសង្គមកិច្ច ប្រាក់របបអ្នកជំងឺ ការប្រាក់សងបំណុល ទឹក ភ្លើង ទូរស័ព្ទ វិភាគទានឱ្យអង្គការអន្តរជាតិនានា និង ចំណាយបដិភាគរួមចំណែកជាមួយការវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស និងបន្ទាប់មកត្រូវផ្អែកលើការទូទាត់ដែលមានចែងក្នុងកិច្ចសន្យាលទ្ធកម្មសាធារណៈ ។ ទន្ទឹមនឹងនេះ គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវបង្កើនការសន្សំសំចៃកម្រិតខ្ពស់ ពិសេសលើចំណាយរដ្ឋបាល ដូចជាប្រេងឥន្ធនៈ សំភារៈការិយាល័យ អគ្គិសនី ទឹក ទូរស័ព្ទ ព្រមទាំងចំណាយរដ្ឋបាលផ្សេងៗ ដោយបង្កើនការគ្រប់គ្រងចំណាយឱ្យកាន់តែមានភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពខ្ពស់ ព្រមទាំងធ្វើអាទិភាពកម្មឡើងវិញ ក្នុងករណីចាំបាច់ដើម្បីត្រៀមកាត់បន្ថយចំណាយដើម្បីរួមចំណែករក្សាតុល្យភាពថវិកា ស្ថិរភាពថ្លៃ ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

១៤- ដើម្បីឱ្យការអនុវត្តចំណាយថវិកាថ្នាក់ជាតិប្រព្រឹត្តទៅបានទាន់ពេលវេលា និង ជៀសវាងការចំណាយតិចនៅដើមឆ្នាំ ហើយទៅប្រមូលផ្តុំចំណាយច្រើននៅចុងឆ្នាំ និង ម្យ៉ាងវិញទៀត ដើម្បីរក្សាតុល្យភាពថវិកាឱ្យបានរឹងមាំផងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈ និង មន្ទីរជំនាញរាជធានី-ខេត្ត ឱ្យដំណើរការអនុវត្តនីតិវិធីចំណាយ ដូចជាការស្នើសុំធានាចំណាយ និង អនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈ ដូចតទៅ:

• រដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែ ត្រូវប្រញាប់ប្រញាល់ធ្វើប្រកាសស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និង ការផ្ទេរឥណទានថវិកាជូនគណៈអភិបាលរាជធានី-ខេត្ត ដើម្បីឱ្យមន្ទីរជំនាញរបស់ខ្លួននៅតាមរាជធានី-ខេត្ត អាចអនុវត្តនីតិវិធីចំណាយបានទាន់ពេលវេលា ។

• ចំណាយថវិកាថ្នាក់ជាតិក្នុងការទិញសំភារៈ ជួលសេវា ជួសជុល និង សាងសង់ ត្រូវតែអនុវត្តឱ្យបានម៉ឺងម៉ាត់តាមគោលការណ៍ និង នីតិវិធីលទ្ធកម្មសាធារណៈ ។ ចំពោះការអនុវត្តនីតិវិធីដេញថ្លៃជាសាធារណៈត្រូវប្រញាប់ប្រញាល់លើកសំណើសុំគោលការណ៍ធានាចំណាយឱ្យបានទាន់ពេលវេលា មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ឱ្យបាននៅដើមឆ្នាំ និង ដើមឆមាស ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ។ កន្លងមក សាមីក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-រាជធានី មានការយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយ ដែលជាហេតុបណ្តាលឱ្យការងារលទ្ធកម្មត្រូវអូសបន្លាយ ហើយការងារទូទាត់ត្រូវពន្យារដល់ចុងឆ្នាំទាំងឱ្យចំណាយកើនឡើងគំហុកនៅចុងឆ្នាំ ។ សូមបញ្ជាក់ថា ការស្នើសុំធានាចំណាយសម្រាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈមិនទាក់ទងដល់កម្មវិធីចំណាយទេ គឺទាក់ទងតែឥណទាន

ថវិកាដែលបានកំណត់នៅក្នុងសៀវភៅថវិកាតែប៉ុណ្ណោះ ប៉ុន្តែកម្មវិធីចំណាយត្រូវតែជាក់ស្តែង និង សុក្រឹត ព្រោះ វាជាមូលដ្ឋានសម្រាប់ការរៀបចំផែនការសាច់ប្រាក់សម្រាប់ការទូទាត់ ។

**ខ.៥ - ការអនុវត្តប្រាក់បៀវត្ស ប្រាក់បំណាច់ និង ប្រាក់ឧបត្ថម្ភផ្សេងៗ**

**១៥**- ចំពោះចំនួនក្របខ័ណ្ឌ និង ប្រាក់បៀវត្សរបស់មន្ត្រីរាជការ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវតែពិនិត្យអនុវត្តទៅតាមតារាងបៀវត្សដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលចេញដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និង រាល់ក្របខ័ណ្ឌគតិយុត្តដែលនៅមានជាធរមាន ពិសេស អនុក្រឹត្យ សារាចរណែនាំ និង សេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត ការត្រួតពិនិត្យឡើងវិញនូវចំនួន និង ការគ្រប់គ្រងមន្ត្រីរាជការ និង ការកែសម្រួលប្រាក់បៀវត្ស ប្រាក់បំណាច់ និង ប្រាក់ឧបត្ថម្ភផ្សេងៗ ជាដើម ។ ក្នុងករណីមានការផ្ទេរមន្ត្រីរាជការពីក្រសួង-ស្ថាប័នមួយទៅក្រសួង-ស្ថាប័នមួយទៀតនៅក្នុងឆ្នាំ សាមីខ្លួនត្រូវបន្តទទួលបៀវត្សនៅក្រសួង-ស្ថាប័នដើមរហូតដល់ដំណាច់ឆ្នាំ ហើយត្រូវធ្វើការផ្ទេរ និង គ្រោងបៀវត្សនៅក្រសួង-ស្ថាប័នដែលបានផ្ទេរចូលឱ្យទាន់ពេលនៅឆ្នាំបន្ទាប់ ។ ដើម្បីឱ្យការប្រើប្រាស់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត មានសង្គតិភាព និង ឯកភាពគ្នានៅគ្រប់ក្រសួង-ស្ថាប័ន ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ តាមសារាចរលេខ ០០១ សហវ, ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១០ ស្តីពីការប្រើប្រាស់ និង ការផ្តល់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត។ ក្រសួងស្ថាប័នសាមីត្រូវសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន លើការជ្រើសមន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត មុននឹងស្នើសុំទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**ខ.៦ - ការផ្ទេរឥណទានថវិកា**

**១៦**- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួន ទៅតាមប្រកាសស្តីពីការបែងចែកចំណាយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដូចមានលម្អិតនៅក្នុងសៀវភៅថវិកា ។ នៅដើមត្រីមាសទី ៣ ក្រោយពីការអនុវត្តត្រីមាសទី ២ ចប់សព្វគ្រប់មក ក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានមិនគ្រប់គ្រាន់តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សម្រេចជាមុនសិន ទើបអាចលើកសំណើសុំខ្ទង់ចំណាយនោះបាន ។ ដើម្បីសម្រួលដល់ការអនុវត្តចំណាយថវិកាកម្មវិធី ត្រូវបានធ្វើប្រតិភូកម្មសិទ្ធិអំណាចដល់អាណាប័កដើមខ្សែ ដែលជាប្រធានក្រសួង-ស្ថាប័ន ក្នុងការធ្វើនិយ័តភាពពីអនុគណនី ទៅអនុគណនីមួយទៀត នៅក្នុងគណនីតែមួយ ។ ការធ្វើនិយ័តភាពថវិកានេះ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួង-ស្ថាប័នសាមី ដោយមានការចុះហត្ថលេខារបស់រដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ដែលជាអាណាប័កដើមខ្សែ ។ បើក្រសួង-ស្ថាប័ន មានសំណូមពរផ្តល់ឥណទានបន្ថែម សម្រាប់ផ្តល់ទៅឱ្យមន្ទីរជំនាញរាជធានី-ខេត្តរបស់ខ្លួន គឺការផ្តល់ឥណទានបន្ថែមនោះ ត្រូវធ្វើឡើងដោយ

ប្រកាសផ្ទេរឥណទានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត (អាណាប័កតាមការប្រទានសិទ្ធិ) ដែលជាខ្សែទទឹង និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចតាមដានការប្រើប្រាស់ឥណទានថវិកាបន្ថែមទាំងនោះបាន ។ ការធ្វើនិយ័តភាពចេញពីថវិកាកម្មវិធីទៅថវិកាមិនមែនកម្មវិធី ឬ ការធ្វើនិយ័តភាពពីកម្មវិធីទៅកម្មវិធីមួយទៀត មិនត្រូវបានផ្តល់ការអនុញ្ញាតជូនទេ សម្រាប់ថវិកាឆ្នាំ ២០១១ នេះ ។

## III. ការត្រួតពិនិត្យតាមដានការអនុវត្តថវិកា និង ការធ្វើរបាយការណ៍

១៧- ពង្រឹងតួនាទីរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់បណ្តាក្រសួងស្ថាប័ននានា និងអគ្គាធិការដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការត្រួតពិនិត្យការអនុវត្តថវិកា ជាពិសេសចំណាយថវិកា ។

១៨- ដើម្បីបង្កើនគណនេយ្យភាព និង ការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈជាពិសេស ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ត្រូវធ្វើការតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និង ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា និង នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ) ឱ្យបានទៀងទាត់ ទៅតាមគំរូដែលបានផ្ញើជូន និង ទៅតាមកាលបរិច្ឆេទដូចខាងក្រោមៈ

- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់
- របាយការណ៍ប្រចាំត្រីមាស ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែនៅដើមត្រីមាសបន្ទាប់
- របាយការណ៍ឆមាសទី១ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ មិថុនា
- របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១២

## IV. វិធានការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

១៩- គ្រប់ក្រសួង-ស្ថាប័ន ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំនីមួយៗរួចរាល់ និងផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) យ៉ាងយូរត្រឹមនៅចុងត្រីមាសទី១ នៃឆ្នាំបន្ទាប់ ។

២០- អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសម្រេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិរបស់រដ្ឋ ចូលក្នុងបញ្ជីសារពើភ័ណ្ឌ ។

## V. វិធានការរក្សាតុល្យភាព និង ប្រសិទ្ធភាពថវិកា

២១- នៅពេលដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តថវិកានឹងមិនអាចសម្រេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាតុល្យភាព និង ប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានវិធានការដូចខាងក្រោមៈ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសហការជាមួយក្រសួងផែនការ និង ធនាគារជាតិ ដើម្បីបន្តបង្កើនការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុ និង សេដ្ឋកិច្ច ក្នុងគោលបំណងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមានពីខាងក្រៅ និង រក្សាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ និង សេដ្ឋកិច្ច នៅកម្ពុជា ។
- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការតាមដានការអនុវត្តថវិកា និង សកម្មភាពការងាររបស់ខ្លួនជាប្រចាំ និង អនុវត្តប្រកបដោយភាពទន់ភ្លន់ទៅតាមសភាពការណ៍ហិរញ្ញវត្ថុ និង សេដ្ឋកិច្ច ដែលបាន និង កំពុងប្រែប្រួលស្ទើរតែមិនអាចព្យាករណ៍បានប្រកបដោយលក្ខណៈសកម្មគ្រប់គ្រង ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យលើការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតម្រូវក្នុងករណីចាំបាច់ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនអនុញ្ញាតឱ្យមានការបោះផ្សាយអាណត្តិតំកល់ទុកសម្រាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ ។

២២-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និង រាជធានី-ខេត្តទាំងអស់នឹងរួមសហការក្នុងការអនុវត្តថវិកាឆ្នាំ ២០១១ របស់យើងឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក ដើម្បីបម្រើឱ្យការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាល ដើម្បី **កំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាព** និង ឆ្លើយតបទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដើម្បី **កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន** ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
«ដើម្បីជូនជ្រាបជាព័ត៌មាន»
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់រាជធានី-ខេត្ត
«ដើម្បីអនុវត្ត»
- រាជកិច្ច
«ដើម្បីផ្សព្វផ្សាយ»
- ឯកសារ- កាលប្បវត្តិ